ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៣៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ៤៤៨ ហិកតា ដែលក្នុងនោះ (១). កាត់ចេញពីឧទ្យានជាតិកែប នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣, (២) ពីគម្របព្រៃឈើ ឆ្នាំ ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវទំហំ ៤២៧ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៤៥ គ្រួសារ និងទំហំ ២១ ហិកតា រក្សាទុកសម្រាប់ជាដីឯកជនរបស់រដ្ឋ សម្រាប់សម្បទានគោលដៅសង្គមកិច្ច និងផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង ចំនួន ២៣៣ គ្រួសារ លើ៤៣៦ ក្បាលដី នៅក្រុងកែប ខេត្តកែប

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១២/១០២៣ ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១២
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ១២៣សណ/ខក ចុះថ្ងៃទី៣០ខែវិច្ឆិកា ឆ្នាំ ២០១២ របស់គណៈកម្មាធិការ គ្រប់គ្រងដីរដ្ឋខេត្តកែប
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីសរុបទំហំ៤៤៨ (បួនរយសែសិបប្រាំបី) ហិកតា ដែលក្នុងនោះ (១). ផ្ទៃដីទំហំ ១៧១ (មួយរយចិតសិបមួយ) ហិកតា កាត់ចេញពីឧទ្យានជាតិកែប តាមរយៈព្រះរាជក្រឹត្យកាត់ចេញពីព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ត្រង់មាត្រា ២ ចំណុច ១ លេខរៀងទី ៣ (២). ផ្ទៃដីទំហំ ២៧៧ ហិកតាពីគម្របព្រៃឈើឆ្នាំ ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនូវដីទំហំ ៤២៧ (បួនរយម្ភៃប្រាំពីរ) ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ប្រើប្រាស់និងដាំដុះជាក់ស្តែង និងទំហំ ២១ (ម្ភៃមួយ)ហិកតា រក្សាទុកជាដីឯកជនរបស់រដ្ឋសម្រាប់សម្បទានគោលដៅសង្គមកិច្ចនៅ ក្រុងកែប ខេត្តកែប ដែលមានទំហំ និងចំនួនគ្រួសារ ស្ថិតនៅក្នុងភូមិ សង្កាត់ ដូចខាងក្រោម ៖

- ផ្ទៃដីសរុបទំហំ ៣២៨ (បីរយម្ភៃប្រាំបី)ហិកតា ក្នុងនោះ (១) ទំហំ ៥១ (ហាសិបមួយ) ហិកតា កាត់ចេញពីឧទ្យានជាតិកែប (២)ទំហំ ២៧៧ (ពីរយចិតសិបប្រាំពីរ) ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៣២២ (បីរយម្ភៃពីរ) ហិកតា សម្រាប់ប្រទានកម្ម

ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ០៦ (ប្រាំមួយ)ហិកតា រក្សាទុកជាដីឯកជនរបស់រដ្ឋសម្រាប់សម្បទានគោលដៅសង្គមកិច្ច នៅភូមិតំណាក់ចង្អើរ សង្កាត់ព្រៃធំ

- ផ្ទៃដីសរុបទំហំ ៤៥ (សែសិបប្រាំ) ហិកតា កាត់ចេញពីឧទ្យានជាតិកែប ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៣០ (សាមសិប) ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋនិងទំហំ ១៥ (ដប់ប្រាំ) ហិកតា រក្សាទុកជាដីឯកជនរបស់រដ្ឋសម្រាប់សម្បទានគោលដៅសង្គមកិច្ច នៅភូមិកំពង់ត្រឡាច សង្កាត់ព្រៃធំ

- ផ្ទៃដីទំហំ ៧៥ (ចិតសិបប្រាំ) ហិកតា កាត់ចេញពីឧទ្យានជាតិកែប ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិកែវក្រសាំង សង្កាត់កែប

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

**មាត្រា២.**

ត្រូវបានប្រគល់អាណត្តិកាន់កាប់និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកែប ធ្វើការគ្រប់គ្រងនិងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ២៤៥ គ្រួសារដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅខេត្តកែប ក្រុងកែប នៅក្នុងភូមិ សង្កាត់ដូចខាងក្រោម ៖

-សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៨០ គ្រួសារ នៅភូមិតំណាក់ចង្អើរ សង្កាត់ព្រៃធំ

-សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៥១ គ្រួសារ នៅភូមិកំពង់ត្រឡាច សង្កាត់ព្រៃធំ

-សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១១៤ គ្រួសារ នៅភូមិកែវក្រសាំង សង្កាត់កែប

**មាត្រា ៣ ..**

ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជន ៤៣៦ ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ២៣៣ គ្រួសារ ស្ថិតនៅក្រុងកែប ខេត្តកែបដូចខាងក្រោម ៖

- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន ១៨៥ ក្បាលដីជូនប្រជាពលរដ្ឋចំនួន ៧៥គ្រួសារ នៅភូមិតំណាក់ចង្អើរ សង្កាត់ព្រៃធំ
- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន ៨០ ក្បាលដីជូនប្រជាពលរដ្ឋចំនួន ៥១គ្រួសារ នៅភូមិកំពង់ត្រឡាច សង្កាត់ព្រៃធំ
- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន ១៧១ ក្បាលដីជូនប្រជាពលរដ្ឋចំនួន ១០៧ គ្រួសារ នៅភូមិកែវក្រសាំង សង្កាត់កែប

**មាត្រា ៤ ..**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកែបត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

**មាត្រា ៥ ..**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកែប ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ៩ ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*